ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ ......០២៩ សណស....../គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីគាំទ្រ តាមដាន និងត្រួតពិនិត្យដំណើរការ រៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩/០៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីជូនដំណឹងលេខ១៧៤ សជណ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំការពិនិត្យ សម្រេចលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីណែនាំលេខ០១៥ សណន/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ស្តីពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"
- បានឃើញសេចក្តីសម្រេចលេខ០១៤ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ស្តីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤

- យោងលិខិតចាត់តាំងសមាសភាពចូលរួមក្នុងក្រុមការងារអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងកិច្ចការនារី និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើត**ក្រុមការងារអន្តរក្រសួង** ដើម្បីគាំទ្រ តាមដាន និងត្រួតពិនិត្យដំណើរការនៃការរៀបចំវេទិការការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី **“កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០”** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម សក់ សេដ្ឋា** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. | ជាប្រធាន |
| ២. **ឯកឧត្តម ចាន់ សុធា** | រដ្ឋលេខាធិការ និងជាប្រធានស្តីទីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣. **លោកជំទាវ គីម ស៊ីផាត់** | រដ្ឋលេខាធិការប្រចាំការ ក្រសួងកិច្ចការនារី | ជាអនុប្រធាន |
| ៤. **ឯកឧត្តម ថោ សេដ្ឋាណា** | រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | ជាអនុប្រធាន |
| ៥. **ឯកឧត្តមបណ្ឌិត ទច់ សណ្តាប់** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៦. **ឯកឧត្តម គួច ពលពន្លក** | ទីប្រឹក្សា ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៧. **ឯកឧត្តម ចេង ម៉ានី** | ទីប្រឹក្សា ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨. **ឯកឧត្តម សូ មុនីរក្សា** | នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩. **ឯកឧត្តម ជ័យ សម្បត្តិដល្លា** | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១០. **ឯកឧត្តម ប៊ុ វឌ្ឍសុខា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១១. **ឯកឧត្តម នួន វិនយ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១២. **ឯកឧត្តម គីម កែវមុនីវ័ត្ត** | អគ្គនាយករងនៃអគ្គនាយកថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១៣. **លោក សារឿន សុគុល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

| | | |
|---|---|---|
| ១៤. លោក អ៊ួច ចន្ធី | ប្រធាននាយកដ្ឋានបុគ្គលិកមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៥. ឯកឧត្តម បួន ហេង | ប្រធាននាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៦. លោក លី យ៉ាសាក់ | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៧. លោក ឆាង ច័យ | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៨. លោក លី ពៅមណីរ័ត្ន | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៩. លោក សរ កុសល | ប្រធាននាយកដ្ឋានផែនការថ្នាក់ក្រោមជាតិ ក្រសួងផែនការ | ជាសមាជិក |
| ២០. លោក ឌិន សុភ័ក | ប្រធាននាយកដ្ឋាន ក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ២១. លោក ប៉ុក សុគន្ធដារ៉ា | អគ្គលេខាធិការ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ជាសមាជិក |
| ២២. លោកស្រី គង់ ប៊ុណ្ណា | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិកា |
| ២៣. លោក ប៊ុន ម៉ានិត | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ២៤. លោក តូច ទិរៈ | អនុប្រធាននាយកដ្ឋានបុគ្គលិកមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២៥. លោក ផន ចាន់រិទ្ធ | អនុប្រធាននាយកដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ២៦. កញ្ញា មៀច សុន្ធារី | អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ ក្រសួងកិច្ចការនារី | ជាសមាជិកា |
| ២៧. លោក ហែម សាមឿន | ប្រធានការិយាល័យ លេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ២៨. លោក ពិសិដ្ឋ សិលា | អនុប្រធានការិយាល័យ លេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ២៩. លោក ថាច់ សាទី | ទីប្រឹក្សាហិរញ្ញវត្ថុ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក។ |

**ប្រការ ២.**_

ក្រុមការងារអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយសេចក្ដីណែនាំនៃដំណើរការរៀបចំវេទិកា និងផែនការសកម្មភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា
- គាំទ្រ តាមដាន និងត្រួតពិនិត្យដំណើរការរៀបចំកិច្ចប្រជុំរបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត ដើម្បីធានាថារដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តអាចចាត់ចែងរៀបចំកិច្ចប្រជុំ កិច្ចការនានា និងវេទិកាថ្នាក់រាជធានី ខេត្ត ស្របតាមការណែនាំរបស់ គ.ជ.អ.ប. និងតាមក្របខ័ណ្ឌពេលវេលាកំណត់
- ចុះត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តមួយចំនួន ក្នុងការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត និងកិច្ចប្រជុំនានា
- រៀបចំសេចក្ដីព្រាងសមាសភាព កម្មវិធី និងរបៀបវារៈនៃវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនប្រធាន គ.ជ.អ.ប. សម្រាប់ស្នើសុំប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ចាត់ចែងរៀបចំវេទិកាវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញតួនាទី ភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធាន គ.ជ.អ.ប.។

**ប្រការ ៣.**_

ក្រុមការងារអន្តរក្រសួងនេះមាន**លេខាធិការដ្ឋាន គ.ជ.អ.ប.** ធ្វើជាសេនាធិការ។

**ប្រការ ៤.**_

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

ក្រុមការងារអន្តរក្រសួងនេះអាចអញ្ជើញក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងដំណើរការងាររបស់ខ្លួន។

**ប្រការ ៥.**_

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងកិច្ចការនារី ក្រសួងផែនការ លេខាធិការដ្ឋាន គ.ជ.អ.ប. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ ចន្ទ ៥រោច ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប.
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ